St Leonard's College

An education for life.

# ថ្លៃឈ្នួល និងការគិតថ្លៃសិស្សអន្តរជាតិ សម្រាប់ឆ្នាំ 2024



# ថ្លៃឈ្នួល និងការគិតថ្លៃសិស្សអន្តរជាតិសម្រាប់ឆ្នាំ 2024

## ថ្លៃឈ្នួលដាក់ពាក្យសុំ

ថ្លៃឈ្នួលដាក់ពាក្យសុំ $300 អូស្ត្រាលី ត្រូវបង់នៅពេលដាក់ពាក្យសុំ។ ថ្លៃឈ្នួលនេះមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។

## ថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ

ថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ $2,400 អូស្ត្រាលី ត្រូវបង់នៅពេលទទួលយកលិខិតផ្តល់ជូន។ ថ្លៃឈ្នួលនេះមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។

## ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ

ឆ្នាំសិក្សាត្រូវបានបែងចែកជាពីរឆមាស (រយៈពេលសិក្សា)។ ឆមាសទី 1 មានត្រីមាសទី 1 និងទី 2 ហើយចាប់ផ្តើមនៅចុងខែមករា និងបន្តរហូតដល់ខែមិថុនា ដោយមានវិស្សមកាលនៅខែមេសា។ ឆមាសទី 2 មានត្រីមាសទី 3 និងទី 4 ហើយចាប់ផ្តើមនៅខែកក្កដា និងបន្តរហូតដល់ដើមខែធ្នូ ដោយមានវិស្សមកាលនៅខែកញ្ញា។

ប្រាក់កក់ថ្លៃឈ្នួលបង្រៀនសម្រាប់អំឡុងពេលសិក្សាដំបូងនៃការចុះឈ្មោះ (50% នៃថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ) និងការគិតថ្លៃនានា ដូចដែលបានពិពណ៌នានៅក្នុងលិខិតផ្តល់ជូន ត្រូវបង់នៅពេលទទួលយកលិខិតផ្តល់ជូន។

បន្ទាប់មក ថ្លៃឈ្នួល និងការគិតថ្លៃផ្សេងទៀតនឹងត្រូវបង់មួយត្រីមាសជាមុន ជាលក្ខណៈបង់សងបណ្តាក់ប្រចាំឆ្នាំស្មើគ្នាពីរ។ កាលបរិច្ឆេទត្រីមាសអាចរកបាននៅត្រង់ កាលបរិច្ឆេទត្រីមាស ឆ្នាំ 2024 (Term Dates 2024) * វិទ្យាល័យ St Leonard's (stleonards.vic.edu.au)។ ថ្លៃឈ្នួលបង្រៀន និងការគិតថ្លៃនានាត្រូវបង់ក្នុងរយៈពេល 30 ថ្ងៃ ចាប់ពីថ្ងៃដែលបានចេញគណនីយ ហើយស្ថិតក្រោមការពិនិត្យឡើងវិញ និងការកែសម្រួលប្រចាំឆ្នាំ។

| កម្រិតថ្នាក់ | ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ 2024 (គិតជាដុល្លារអូស្ត្រាលី) |
|---|---|
| ថ្នាក់ត្រៀម | $25,204 |
| 1 | $28,646 |
| 2 | $28,646 |
| 3 | $32,115 |
| 4 | $32,115 |
| 5 | $34,756 |
| 6 | $34,756 |
| 7 | $40,215 |
| 8 | $44,562 |
| 9 | $44,562 |
| 10 | $44,869 |
| 11 | $47,504 |
| 12 | $46,881 |

**ថ្លៃឈ្នួលពិសោធន៍ដ៏ធំសម្រាប់កម្មវិធីសហគមន៍ ក្រុង និងបរិស្ថាន (CUE Big Experience) (ប្រហែល $4,000-$6,000) សម្រាប់សិស្សថ្នាក់ទី 9 ដែលមានសិទ្ធិទទួល និងថ្លៃដំណើរសិក្សាជាក្រុមទៅកាន់ទីក្រុងខែនបឺរ៉ា (Canberra) (ប្រហែល $1,500) មិនបានរាប់បញ្ចូលទេ។*

**ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ផ្តល់សម្រាប់កម្មវិធីសិក្សាស្នូល (សំខាន់ចាំបាច់) និងកម្មវិធីសកម្មភាពក្រៅកម្មវិធីសិក្សានៅវិទ្យាល័យ។ ការរួមបញ្ចូលត្រូវបានរៀបរាប់នៅក្នុងលក្ខខណ្ឌអាជីវកម្មរបស់វិទ្យាល័យ។*

*សិស្សក្នុងស្រុក ពលរដ្ឋអូស្ត្រាលី និងអ្នកកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងអចិន្ត្រៃយ៍ គួរស្វែងរកព័ត៌មានពីគេហទំព័ររបស់វិទ្យាល័យ សម្រាប់ព័ត៌មានលម្អិតអំពីថ្លៃឈ្នួល និងការគិតថ្លៃផ្សេងទៀតដែលអាចអនុវត្តបាន។*

## ការធានារ៉ាប់រងសុខភាព

ដូចដែលបានតម្រូវដោយរដ្ឋាភិបាលអូស្ត្រាលី សិស្សអន្តរជាតិ ត្រូវបានតម្រូវឱ្យទិញការធានារ៉ាប់រងសុខភាពឯកជនសម្រាប់រយៈពេលទិដ្ឋាការសិស្សទាំងមូលរបស់ពួកគេ មុនពេលមកដល់ប្រទេសអូស្ត្រាលី។

វិទ្យាល័យ St Leonard's នឹងទិញការធានារ៉ាប់រងនេះក្នុងតម្លៃ $692 អូស្ត្រាលីក្នុងមួយឆ្នាំ (ឬដូចដែលបានណែនាំដោយក្រុមហ៊ុន BUPA ឬអ្នកផ្តល់សេវាកម្មដែលបានជ្រើសរើសរបស់វិទ្យាល័យ) ជំនួសឱ្យសិស្ស ហើយនឹងចេញវិក្កយបត្រចំនួននេះ នៅពេលចេញលិខិតផ្តល់ជូន។

សិស្សដែលនៅបន្តការសិក្សា នឹងត្រូវបានចេញវិក្កយបត្រប្រចាំឆ្នាំចំនួន $692 អូស្ត្រាលី (ការប៉ាន់ស្មានបច្ចុប្បន្ន) និងនៅពេលការធានារ៉ាប់រងរបស់ពួកគេត្រូវបន្តជាថ្មី។

## ការចំណាយបន្ថែម

ការចំណាយបន្ថែមអាចអនុវត្តសម្រាប់កម្មវិធីមួយចំនួន ដែល មិនសំខាន់ចាំបាច់ ឬកម្មវិធីដែលអាចជ្រើសរើសបាន ឧទាហរណ៍ ការបោះជំរំវិស្សមកាលជាជម្រើស និងមេរៀនតន្ត្រីនីមួយៗ។ បញ្ជីនៃកម្មវិធីដែលមិនសំខាន់ចាំបាច់ ត្រូវបានរៀបរាប់នៅក្នុងលក្ខខណ្ឌអាជីវកម្មរបស់វិទ្យាល័យ។

សូមកត់សម្គាល់ថា ការចំណាយបន្ថែមទៀតទាក់ទងនឹងការចុះឈ្មោះចូលរៀននៅវិទ្យាល័យ St Leonard's នឹងត្រូវចំណាយសម្រាប់ការទិញឯកសណ្ឋានសាលា សៀវភៅ និងសម្ភារៈសិក្សា ហើយនិងឧបករណ៍កីឡា ឬឧបករណ៍តន្ត្រីណាមួយដែលអាចតម្រូវ។

វិទ្យាល័យក៏មានបទបញ្ញត្តិលើគំរូបច្ចេកវិទ្យា 'យកឧបករណ៍ផ្ទាល់ខ្លួនរបស់អ្នក' (BYOD) របស់សិស្សផងដែរ។ សិស្សថ្នាក់ទី 10 ទៅ 12 ផ្ទាំអាចជ្រើសរើសបច្ចេកវិទ្យាដែលសមស្របបំផុត តាមតម្រូវការរបស់ពួកគេ។ សិស្សថ្នាក់ទី 9 និងថ្នាក់ក្រោមនេះ នឹងតម្រូវឱ្យមាន iPad។

តម្រូវការអប្បបរមានៃឧបករណ៍ អាចមើលនៅតាមគេហទំព័រ learn.stleonards.vic.edu.au/ipad/

បញ្ជីថ្លៃឈ្នួល និងការគិតថ្លៃនេះ មិនរាប់បញ្ចូលការចំណាយក្នុងការរស់នៅផ្សេងទៀត ដែលរួមមានថ្លៃចំណាយលើទូរសព្ទ ថ្នាំពេទ្យ គ្រឿងសំអាង ការធ្វើដំណើរ ការកម្សាន្ត និងលុយដាក់តាមហោប៉ៅផ្សេងៗឡើយ។

## សេចក្តីសង្ខេបនៃថ្លៃឈ្នួលប្រចាំឆ្នាំសម្រាប់ឆ្នាំ 2024 (ឧទាហរណ៍)

| ការគិតថ្លៃ | ចំនួនទឹកប្រាក់ (អូស្ត្រាលី) |
|---|---|
| ថ្លៃឈ្នួលដាក់ពាក្យសុំ * | $300 |
| ថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះសិស្សអន្តរជាតិ * | $2,400 |
| ថ្លៃឈ្នួលបង្រៀន (ថ្នាក់ទី 12) | $48,874 |
| ការធានារ៉ាប់រងសុខភាព | $654 |
| **សរុប** | **$73,228** |
| វិភាគទានមូលនិធិសាងសង់ដោយស្ម័គ្រចិត្ត | $460 |

*តម្លៃនៃការដាក់ពាក្យ និងការចូលរៀនគឺជាការបង់ប្រាក់ម្តង ហើយត្រូវបានបង់នៅពេលចុះឈ្មោះ។

## វិធីទូទាត់ប្រាក់

គណនីអាចបានបង់ជាទឹកប្រាក់អូស្ត្រាលីដោយៈ

- BPay
- ប័ណ្ណឥណទាន - ( ទទួលយកតែ MasterCard ឬ Visa ប៉ុណ្ណោះ មិនត្រូវបានទទួលយកប័ណ្ណឥណទានពីក្រៅប្រទេសទេ )
- ប្រតិបត្តិការប័ណ្ណឥណពន្ធ ឬការផ្ទេរប្រាក់តាមអេឡិចត្រូនិក

**វិទ្យាល័យមិនទទួលយកការទូទាត់ជាសាច់ប្រាក់ទេ។**

## គោលនយោបាយសងប្រាក់វិញ

ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលចុះឈ្មោះមិនអាចសងវិញបានទេ ប្រសិនបើការដាក់ពាក្យសុំរបស់សិស្សត្រូវបានលុបចោល។

1. កន្លែងណាដែលការចុះឈ្មោះត្រូវបានដកចេញជាលាយលក្ខណ៍អក្សរច្រើនជាងមួយត្រីមាស មុនកាលបរិច្ឆេទចាប់ផ្តើម ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃឈ្នួល Homestay ដកចេញថ្លៃលុបចោល $1,000 អាចសងវិញបាន។ ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ គឺមិនអាចអាចសងវិញបានទេ ហើយក៏មិនអាចផ្ទេរបានឡើយ។
2. កន្លែងណាដែលការចុះឈ្មោះត្រូវបានដកចេញជាលាយលក្ខណ៍អក្សរតិចជាងមួយត្រីមាស កាលបរិច្ឆេទចាប់ផ្តើម ថ្លៃដាក់ពាក្យសុំ ថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ រួមជាមួយនឹង 25% នៃថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ គឺមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃឈ្នួល Homestay អាចសងវិញបាន។។
3. កន្លែងណាដែលភស្តុតាងត្រូវបានផ្តល់ឱ្យ ថាពាក្យសុំទិដ្ឋាការត្រូវបានបដិសេធដោយក្រសួងកិច្ចការផ្ទៃក្នុងរបស់ប្រទេសអូស្ត្រាលី ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃ Homestay គឺអាចសងវិញបាន។ ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ គឺមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។
4. បន្ទាប់ពីការចាប់ផ្តើមចុះឈ្មោះចូលរៀននៅវិទ្យាល័យ ហើយកន្លែងណាដែលមិនបានផ្តល់ការជូនដំណឹង ក្នុងត្រីមាសសាលាពេញអំពីការដកចេញពាក្យសុំទនោះ ការគិតថ្លៃស្មើនឹងថ្លៃឈ្នួលមួយត្រីមាសនឹងត្រូវអនុវត្ត។
5. ប្រសិនបើសិស្សផ្លាស់ប្តូរស្ថានភាពទិដ្ឋាការ ( ឧទាហរណ៍ ក្លាយជាអ្នកស្នាក់នៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ) ថ្លៃឈ្នួលសិស្សអន្តរជាតិពេញលេញនឹងនៅតែត្រូវបង់សម្រាប់អំឡុងពេលនៃឆមាសនោះ។
6. ការសងប្រាក់វិញទាំងអស់នឹងត្រូវគិតជាប្រាក់ដុល្លារអូស្ត្រាលី ហើយនឹងត្រូវបង់ជូនភាគីដើមដែលបានធ្វើការទូទាត់ប្រាក់។
7. ដើម្បីទាមទារការសងប្រាក់វិញ សិស្សត្រូវជូនដំណឹងទៅអ្នកគ្រប់គ្រងទទួលចូលសិស្សអន្តរជាតិជាលាយលក្ខណ៍អក្សរ អំពីគោលបំណងរបស់ពួកគេក្នុងការលុបចោលការចុះឈ្មោះ និងទាមទារការសងប្រាក់វិញ។ បន្ទាប់ពីទទួលបានការជូនដំណឹង កន្លែងណាដែលបានយល់ព្រមការសងប្រាក់វិញនឹងត្រូវដំណើរការ ហើយបញ្ចប់ក្នុងរយៈពេលប្រាំមួយសប្តាហ៍គិតចាប់ពីថ្ងៃទទួល។
8. កិច្ចព្រមព្រៀងនេះមិនដកសិទ្ធិរបស់វិទ្យាល័យ ក្នុងការចាត់វិធានការបន្ថែមដើម្បីប្រមូលថ្លៃឈ្នួល និងការគិតថ្លៃណាមួយដែលនៅជំពាក់វិទ្យាល័យឡើយ។
9. កិច្ចព្រមព្រៀងនេះ និងភាពអាចរកបាននៃដំណើរការបណ្តឹងតវ៉ា និងបណ្តឹងតវ៉ាមិនយល់ស្របរបស់វិទ្យាល័យ មិនដកសិទ្ធិរបស់សិស្សក្នុងការចាត់វិធានការក្រោមច្បាប់ការពារអ្នកប្រើប្រាស់របស់ប្រទេសអូស្ត្រាលីទេ។